# សិក្ខាសាលាបណ្តុះបណ្តាល
# ស្តីពី
# សុវត្ថិភាពឧស្សាហកម្ម

នាព្រឹកថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅទីស្តីការក្រសួងឧស្សាហកម្ម និងសិប្បកម្ម នាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា បានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមទេសរដ្ឋមន្ត្រី** ដើម្បីបើកវគ្គបណ្តុះបណ្តាលដល់វិស័យឯកជន ស្តីពី **"សុវត្ថិភាពឧស្សាហកម្ម"** ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **ទឹង ស៊ីនី** អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិត **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

វគ្គបណ្តុះបណ្តាលនេះធ្វើឡើងក្នុងគោលបំណងចែករំលែកចំណេះដឹង និងបទពិសោធន៍ ស្តីពីការគ្រប់គ្រង ការថែទាំ ការត្រួតពិនិត្យ និងផ្សព្វផ្សាយពីបទបញ្ញត្តិនានា នៃការគ្រប់គ្រងគ្រឿងចក្រគ្រឿងម៉ាស៊ីនដែលមានហានិភ័យក្នុងរោងចក្រ សិប្បកម្ម ជូនវិស័យឯកជន ជាពិសេសដល់កម្មករ អ្នកបញ្ជាឡចំហាយ អ្នកបញ្ជាគ្រឿងចក្រ គ្រឿងម៉ាស៊ីន ដែលមានហានិភ័យឲ្យបានយល់ដឹងពីការគ្រប់គ្រងសុវត្ថិភាព និងប្រសិទ្ធិភាពក្នុងការអនុវត្តន៍ការងារឲ្យបានសមស្របតាមលក្ខណៈបច្ចេកទេស ដើម្បីបញ្ចៀស និងបង្ការគ្រោះថ្នាក់ដែលអាចកើតឡើងនៅទីកន្លែងផលិតកម្ម ធ្វើឲ្យបាត់បង់អាយុជីវិតកម្មករ និងខូចខាតទ្រព្យសម្បត្តិសាធារណៈ និងដើម្បីធានាឲ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។ វគ្គបណ្តុះបណ្តាលនេះមានសិក្ខាកាមចូលរួមចំនួនសរុប៥៨រូប មកពីរោងចក្រចំនួន០៧ នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តស្វាយរៀង និងខេត្តបន្ទាយមានជ័យ។

សិក្ខាសាលាបណ្តុះបណ្តាលបានបញ្ចប់នៅវេលាម៉ោង ១៧:០០ នាទីរសៀល នាថ្ងៃខែឆ្នាំដដែលប្រកបដោយការភាពស្និតស្នាល និងមានការទទួលខុសត្រូវខ្ពស់។

សូមចុចLink ដើម្បីមើលវីឌីអូ https://www.youtube.com/watch?v=NWg_h8kr81Q




២-ប្រភេទ និងលក្ខណៈពិសេស
1. បែងចែកប្រភេទឡចំហាយតាមប្រភេទបំពង់
1.1. ឡចំហាយប្រភេទបំពង់ភ្លើង
CUT AWAY VIEW



